# ព្រំដែននៃសេរីភាព

## ក. សេរីភាព និងសេរីភាពរបស់អ្នកដទៃ

សេរីភាពពេញលេញដែលគ្មានព្រំដែន មានន័យថាៈ

**មនុស្សម្នាក់ៗ អាចធ្វើអ្វីទាំងអស់ដែលខ្លួនចង់ធ្វើ ។**

ប៉ុន្តែសេរីភាព ត្រូវបានកំណត់ ព្រំដែន ដោយសេរីភាពរបស់អ្នកដទៃ ដែលគេក៏មានសិទ្ធិដូចគ្នានេះដែរ គឺៈ

**មនុស្សម្នាក់ៗអាចធ្វើអ្វីទាំងអស់ដែលខ្លួនចង់ធ្វើ**

ដរាបណាតែ

**គេមិនប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់មនុស្សម្នាក់ទៀត ។**

ឧទាហរណ៍ៈ មនុស្សគ្រប់គ្នាអាចចាក់ភ្លេងឮៗប្រសិនបើគេចង់ ប៉ុន្តែគេមិនអាចចាក់នៅពេលយប់នៅពេលអ្នកដទៃត្រូវការទទួលទានដំណេកឡើយ ។ ក្នុងករណីនេះ សិទ្ធិក្នុងការទទួលទានដំណេកឱ្យបានគ្រប់គ្រាន់បានកំណត់ព្រំដែនចំពោះសិទ្ធិក្នុងការស្តាប់ភ្លេងឮៗ ។

សិទ្ធិ និងសេរីភាពនេះ មានចែងនៅក្នុងអត្ថបទច្បាប់ជាច្រើន ដូចជាៈ

មាត្រា៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧ៈ

"សេរីភាពគឺជាអំណាចក្នុងការធ្វើអ្វីៗ កុំឱ្យតែប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ ។"

មាត្រា៣១ II ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣(CC)ៈ

"ការប្រើប្រាស់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។"

មាត្រា៤ នៃសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្សរបស់បារាំង (ឆ្នាំ១៧៨៩)

សេរីភាព រួមមានការដែលអាចធ្វើអ្វីៗទាំងអស់ដែលមិនប៉ះពាល់ដល់អ្នកដទៃ ។ ដូច្នេះការអនុវត្តសិទ្ធិពីធម្មជាតិរបស់មនុស្សម្នាក់ៗគ្មានព្រំដែនឡើយ លើកលែងព្រំដែនដែលធានាថាសមាជិកដទៃទៀតនៅក្នុងសង្គមទទួលបាននូវសិទ្ធិដូចគ្នានេះដែរ ព្រំដែននេះអាចត្រូវគេកំណត់ដោយច្បាប់តែប៉ុណ្ណោះ ។

## ២. ព្រំដែនកំណត់នៃសេរីភាពគឺច្បាប់:

ការការពារទំនាស់សិទ្ធិមួយទៅនឹងសិទ្ធិមួយទៀត ត្រូវតែមានតុល្យភាព ។ តុល្យភាពអាចកើតមានឡើងទាល់តែមានការដាក់កំហិតលើសិទ្ធិដែលមានការអនុវត្តន៍ខ្លាំងពេក ។ មានតែច្បាប់ប៉ុណ្ណោះដែលអាចកំណត់ព្រំដែននៃសេរីភាព និងសិទ្ធិរបស់មនុស្សម្នាក់ ។ ច្បាប់នេះត្រូវមានគោលបំណងការពារសេរីភាពរបស់មនុស្សម្នាក់ទៀត ។

**មនុស្សម្នាក់ៗ អាចធ្វើអ្វីទាំងអស់ដែលខ្លួនចង់ធ្វើ**

ដរាបណា

**វាមិនត្រូវបានឃាត់ឃាំងច្បាស់លាស់ដោយច្បាប់ដែលការពារសិទ្ធិរបស់មនុស្សម្នាក់ទៀត ។**

សិទ្ធិនេះក៏មានចែងនៅក្នុងអត្ថបទច្បាប់មួយចំនួន ដូចជា:

> មាត្រា៣១ II ចំនុចទី២ និងទី៣ CC:
>
> " ការប្រើប្រាស់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើប្រាស់សិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។"

> មាត្រា២៩ II នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UDHR):
>
> "ក្នុងការប្រតិបត្តិសិទ្ធិសេរីភាពទាំងឡាយ មនុស្សម្នាក់ៗគ្រាន់តែស្ថិតក្នុងព្រំដែនដែលច្បាប់បានកំណត់ប្រយោជន៍ឱ្យមានការទទួលស្គាល់ និងគោរពដល់សិទ្ធិ និងសេរីភាពទាំងឡាយរបស់អ្នកដទៃ និង ដើម្បីឆ្លើយតបនឹងតម្រូវការទាមទារនៃសីលធម៌នៃរបៀបរៀបរយសាធារណៈ និង នៃសុខមាលភាពទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យ ។"

> មាត្រា៤ នៃសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្សរបស់បារាំង ឆ្នាំ១៧៨៩:
>
> សេរីភាព រួមមានការដែលអាចធ្វើអ្វីៗទាំងអស់ដែលមិនប៉ះពាល់ដល់អ្នកដទៃ ។ ដូច្នេះការអនុវត្តសិទ្ធិពីធម្មជាតិរបស់មនុស្សម្នាក់ៗគ្មានព្រំដែនឡើយ លើកលែងព្រំដែនដែលធានាថាសមាជិកដទៃទៀតនៅក្នុងសង្គមទទួលបាននូវសិទ្ធិដូចគ្នានេះដែរ ព្រំដែននេះអាចត្រូវគេកំណត់ដោយច្បាប់តែប៉ុណ្ណោះ ។

## គ. សេរីភាពមិនត្រូវការការអនុញ្ញាតឡើយ

និយមន័យនៃសេរីភាពចែងថា:

**អ្វីៗទាំងអស់ត្រូវបានអនុញ្ញាត**
**លើកលែងតែវាត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់ដោយច្បាប់ ។**

> មាត្រា៥ នៃសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្សរបស់បារាំងឆ្នាំ១៧៨៩:
>
> " ...គ្មានអ្វីដែលមិនត្រូវបានច្បាប់ហាមឃាត់ ត្រូវគេរារាំងឡើយ ហើយគ្មាននរណាម្នាក់ត្រូវគេបង្ខំឱ្យធ្វើអ្វីមួយដែលច្បាប់មិនបានចែងនោះឡើយ ។"

និយមន័យនេះ ត្រូវគេចែងផ្ទុយទៅវិញនៅក្នុងប្រទេសដែលគ្មានសេរីភាព គឺ:

**អ្វីៗទាំងអស់ត្រូវបានហាមឃាត់ លើកលែងតែវាត្រូវបានរដ្ឋអនុញ្ញាតយ៉ាងច្បាស់លាស់ដោយរដ្ឋ ។**

ដូច្នេះ វាមានចំណុចខុសគ្នារវាងសង្គមសេរី និងមិនសេរី:

| **ក្នុងប្រទេសសេរី** | **ក្នុងប្រទេសមិនសេរី** |
|---|---|
| ច្បាប់ជាទូទៅគឺ:<br>អ្វីៗទាំងអស់ត្រូវបានអនុញ្ញាត (ដោយការធានាដល់សេរីភាពទូទៅនៃអំពើដែលចែងក្នុងរដ្ឋធម្មនុញ្ញ មាត្រា៣១ II) | ច្បាប់ជាទូទៅគឺ:<br>អ្វីៗទាំងអស់ត្រូវគេហាមឃាត់ (ដោយអំណាចរបស់រដ្ឋ) |
| ការលើកលែងគឺ:<br>មានតែសកម្មភាពមួយចំនួនដែលត្រូវច្បាប់ហាមឃាត់ក្នុងករណីពិសេស ។ | ការលើកលែងគឺ:<br>មានតែសកម្មភាពមួយចំនួន ដែលរដ្ឋឱ្យធ្វើ ដោយត្រូវសុំច្បាប់អនុញ្ញាតពិសេសមួយ ។ |
| ផលវិបាកគឺ:<br>ជាទូទៅ គ្មាននរណាម្នាក់ចាំបាច់ត្រូវសុំច្បាប់អនុញ្ញាត ឬការឯកភាពពីរដ្ឋអំណាច មុននឹងខ្លួនត្រូវធ្វើអ្វីមួយនោះឡើយ ។<br><u>លើកលែងនៅក្នុងករណីខ្លះ ដែលច្បាប់ចែងថាចាំបាច់ត្រូវសុំច្បាប់អនុញ្ញាតនោះ</u> | ផលវិបាកគឺ:<br>ជាទូទៅមនុស្សគ្រប់គ្នាត្រូវសុំច្បាប់អនុញ្ញាតពីរដ្ឋអំណាចមុននឹង ខ្លួនធ្វើអ្វីមួយ ។ |

អាស្រ័យដោយប្រទេសកម្ពុជា ជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យសេរី (សូមអានមាត្រា១ I, ៥១ I CC) ហើយផ្តល់សេរីភាពទូទៅ (មាត្រា៣១ III CC) កម្ពុជា គឺជាប្រទេសសេរី ។

ព្រោះហេតុដូច្នេះ អ្វីៗទាំងអស់ត្រូវបានអនុញ្ញាតដោយសិទ្ធិមនុស្សជាមូលដ្ឋានដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ ។ ហេតុដូច្នេះហើយវិធានដូចខាងក្រោមត្រូវអនុវត្តៈ

**គ្មាននរណាម្នាក់នៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវសុំច្បាប់អនុញ្ញាតពិសេស ពីរដ្ឋអំណាច មុននឹងគេធ្វើអ្វីឡើយ**

**លើកលែង**

**ច្បាប់បានចែងយ៉ាងច្បាស់លាស់ថាគេត្រូវសុំច្បាប់អនុញ្ញាតបែបនេះ ដើម្បីការពារសិទ្ធិរបស់មនុស្សដទៃ!**

ឧទាហរណ៏ៈ

- គ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាចង់បង្កើតសមាគមគ្រូបង្រៀនមួយ ។ ពួកគេបានប្រមូលផ្តុំគ្នា ដើម្បីរៀបចំបង្កើតសមាគមនេះ ។ ពេលនោះប៉ូលីសបានឡោមព័ទ្ធពួកគេ ហើយប្រាប់គេថាការប្រជុំគ្នានេះខុសច្បាប់ ព្រោះគេមិនបានសុំច្បាប់អនុញ្ញាតដើម្បីបង្កើតសមាគម ។

ការធ្វើដូច្នេះ មិនត្រឹមត្រូវឡើយព្រោះៈ

ពួកគ្រូបង្រៀនមិនចាំបាច់សុំច្បាប់អនុញ្ញាតពិសេសពីរដ្ឋអំណាច ដើម្បីបង្កើតសមាគមឡើយ ។ សិទ្ធិរបស់គេជាមូលដ្ឋានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញទាក់ទងនឹងការបង្កើតសមាគម (មាត្រា ៤២ I , II CC ) បានផ្តល់អោយពួកគេនូវសេរីភាពទូទៅ ដើម្បីធ្វើដូច្នេះបាន ។ សេរីភាពនេះមិនត្រូវបានកំណត់ព្រំដែនដោយច្បាប់ពិសេសណាមួយដែលទាមទារអោយពួកគេសុំច្បាប់អនុញ្ញាត ដើម្បីបង្កើតសមាគមនោះឡើយ ។ ច្បាប់ណាមួយដែលកំណត់ព្រំដែនសេរីភាពរបស់ពួកគេក្នុងការបង្កើតសមាគម គឺជាច្បាប់ដែលខុសរដ្ឋធម្មនុញ្ញ ពីព្រោះ ច្បាប់នេះមិនអាចមានបំណងការពារសិទ្ធិមនុស្សដទៃទៀតឡើយ អាស្រ័យដោយការបង្កើតសមាគមគ្រូបង្រៀនមិនប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់មនុស្សដទៃទៀតឡើយ ។

- នៅក្នុងករណីជាច្រើន គណបក្សនយោបាយផ្សេងៗ ចង់លើកផ្លាកសញ្ញាគណបក្សនៅខាងមុខផ្ទះសមាជិកគណបក្សនៅតាមភូមិនានាក្នុងខេត្ត ។ រដ្ឋអំណាចមូលដ្ឋានបានបញ្ជាឱ្យសមាជិកគណបក្សដកផ្លាកសញ្ញាចេញ ហើយគំរាមថាគេនឹងទទួលផលវិបាកបើហ៊ានធ្វើដូច្នេះ ។ រដ្ឋអំណាចអះអាងថាការលើកផ្លាកសញ្ញាគណបក្សនោះជាការខុសច្បាប់ ពីព្រោះសមាជិកគណបក្សមិនបានសុំច្បាប់អនុញ្ញាតដើម្បីដាក់ផ្លាកសញ្ញានេះឡើយ ។ ពួកគេនិយាយថាគេអាចផ្តល់ច្បាប់អនុញ្ញាតឱ្យធ្វើដូច្នេះ ក្នុងករណីដែលគណបក្សបានដាក់ការិយាល័យក្នុងកម្រិតស្រុកតែប៉ុណ្ណោះ ឬក៏សមាជិកគណបក្សបានបង់ថ្លៃមួយចំនួន ឬក៏ប្រសិនបើមានការយល់ព្រមពីក្រសួងមហាផ្ទៃជាដើម ។

ការធ្វើដូច្នេះមិនត្រឹមត្រូវឡើយព្រោះៈ

សមាជិកគណបក្សនយោបាយមិនចាំបាច់សុំច្បាប់អនុញ្ញាតពិសេស ដើម្បីលើកផ្លាកសញ្ញាគណបក្សឡើយ ព្រោះជាទូទៅរដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យប្រជាជនកម្ពុជាបង្កើតគណបក្សនយោបាយ (មាត្រា ៤២ I CC )។ ដើម្បី

ឱ្យកាន់តែមានអត្ថន័យ ខដែលចែងក្នុងរដ្ឋធម្មនុញ្ញនេះមានរួមបញ្ចូលសកម្មភាពទាំងអស់ដែលជំរុញឱ្យគេអាចសំរេចបាននូវគោលបំណងរបស់គណបក្ស ។ ការដាក់ផ្លាកសញ្ញាគណបក្ស គឺជាសកម្មភាពបែបនេះយ៉ាងច្បាស់លាស់ ។ ច្បាប់ស្តីពីគណបក្សនយោបាយគ្រាន់តែតម្រូវឱ្យគណបក្សនយោបាយទៅចុះបញ្ជីឈ្មោះគណបក្សតែប៉ុណ្ណោះ ប៉ុន្តែមិនមានចែងថាគេត្រូវសុំច្បាប់អនុញ្ញាតពិសេស ដើម្បីដាក់ផ្លាកសញ្ញាគណបក្សឡើយ ។ ផ្ទុយមកវិញ មាត្រា៩ III នៃច្បាប់ស្តីពីគណបក្សនយោបាយ បានអនុញ្ញាតឱ្យគណបក្ស អាចលើកផ្លាកសញ្ញាគណបក្សតាំងពីពេលចុះឈ្មោះមកម្ល៉េះ ។ គណបក្សណាក៏ដោយដែលបានចុះឈ្មោះអាចធ្វើអ្វី១ទាំងអស់ដែលខ្លួនចង់ធ្វើ ដើម្បីផ្សព្វផ្សាយនូវគោលបំណងរបស់ខ្លួន ។ ប្រសិនបើសកម្មភាពនេះរំលោភសិទ្ធិរបស់អ្នកដទៃ ដូចជាថាគេបានដាក់ផ្លាកសញ្ញាគណបក្សនៅកណ្តាលផ្លូវហើយបង្កគ្រោះថ្នាក់ដល់ចរាចរ ពេលនោះរដ្ឋអំណាចអាចបញ្ជាឱ្យគេយកវាចេញដើម្បីការពារសិទ្ធិរបស់អ្នកធ្វើចរាចរ ។ ប៉ុន្តែ គេមិនអាចអះអាងថាការលើកផ្លាកនេះខុសច្បាប់ ដោយសារតែគ្មានការអនុញ្ញាតនោះទេ អាជ្ញាធរអាចបញ្ជាឱ្យដកផ្លាកនោះចេញ ពីព្រោះវាជាការរំខានដល់ចរាចរជាការខុសច្បាប់ (សូមអានមាត្រា៥២, ច្បាប់ស្តីអំពីការធ្វើចរាចរផ្លូវគោក) ។

## ឃ. កម្រិតកំពូលនៃព្រំដែនសេរីភាព

ប្រសិនបើបុគ្គល "ក" រំខាន និងរំលោភសិទ្ធិ និងសេរីភាពរបស់បុគ្គល "ខ" ពេលនោះច្បាប់ត្រូវកំណត់ព្រំដែនសេរីភាពរបស់បុគ្គល "ក" ដើម្បីការពារសេរីភាពរបស់បុគ្គល "ខ" ។ ដូច្នេះ វាចោទជាសំណួរមួយថា: **តើការដាក់កំហិតនេះត្រូវមានព្រំដែនខ្ពស់បំផុតក៏រិតណា?**

ចម្លើយគឺ: **ការដាក់កំហិតនេះអាចធ្វើត្រឹមកម្រិតមួយ ដែលវាចាំបាច់បំផុត ដើម្បីឱ្យមានតុល្យភាពរវាងសិទ្ធិរបស់បុគ្គល"ក" និងសិទ្ធិរបស់បុគ្គល"ខ" ។**

ហេតុផលគឺ : សិទ្ធិរបស់បុគ្គល "ក" ជាមូលដ្ឋាន មានតម្លៃស្មើនឹងសិទ្ធិរបស់បុគ្គល "ខ" ។ នេះមានន័យថាសេរីភាពរបស់ បុគ្គល"ក" មិនមែនត្រូវលះបង់ទាំងស្រុង គ្រាន់តែដើម្បីការពារបុគ្គល"ខ"នោះឡើយ ។

<u>ឧទាហរណ៏:</u>

នៅពេលដែលបុគ្គល "ក" ចាក់ភ្លេងឮ១នៅពេលយប់ ប៉ុន្តែបុគ្គល "ខ" ចង់សម្រាក ។ ពោលនោះ ទំនាស់នេះអាចដោះស្រាយដោយបទបញ្ញត្តិមួយថា: បុគ្គល "ខ" ត្រូវទ្រាំនឹងសម្លេងឡូឡាហូតដល់ម៉ោង៩យប់ ។ ប៉ុន្តែពេលនោះបុគ្គល "ក" ត្រូវតែឈប់ចាក់ភ្លេង ពីព្រោះបុគ្គល "ខ" ត្រូវការទទួលទានដំណេកពេកពេលយប់ ។ សិទ្ធិរបស់គាត់ក្នុងការថែរក្សាសុខភាពរបស់ខ្លួន មានទម្ងន់ធ្ងន់ជាងសិទ្ធិរបស់បុគ្គល "ក" មិនអាចចាក់ភ្លេងបន្ទាប់ពីម៉ោង៩យប់ វាគ្រាន់តែប៉ះពាល់ដល់ការសប្បាយរបស់គេតែប៉ុណ្ណោះ គឺមិនប៉ះពាល់ដល់សុខភាពនោះទេ ។

ដូច្នេះ វាត្រូវតែមានដំណើរការមួយដើម្បីថ្លឹងថ្លែងសិទ្ធិអោយមានតុល្យភាព ។ ការកម្រិតព្រំដែនសេរីភាពអាចធ្វើទៅបានប្រសិនបើវាចាំបាច់តែប៉ុណ្ណោះ ។ នេះមានន័យថាការកម្រិតព្រំដែននេះអាចធ្វើទៅបាន លុះត្រាណាគ្មានមធ្យោបាយធូរស្រាលណាផ្សេងទៀត ដើម្បីសម្រេចបំណងតែមួយទេនោះ។ ការដាក់កំហិតត្រូវតែ**សមាមាត្រ** គោលបំណងនៃការដាក់កំហិតនេះ គឺដើម្បីការពារសិទ្ធិរបស់មនុស្សម្នាក់ ។ ប៉ុន្តែគោលបំណងល្អនេះ មិនមែន

មានន័យថាគេអាចប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីសម្រេចនូវគោលដៅនេះឡើយ ។ **វាត្រូវតែមានតុល្យភាពមួយរវាងគោលបំណងនៃការដាក់កំហិត និងមធ្យោបាយដែលគេអនុវត្ត** ។ ការថ្លឹងថ្លែងតុល្យភាពនេះត្រូវគេហៅថា:

## "គោលការណ៍នៃភាពសមាមាត្រ"

**គោលការណ៍នៃភាពសមាមាត្រ**

គោលកាណ៍នៃភាពសមាមាត្រ រួមមានធាតុផ្សំពីរគឺៈ

**ភាពសមស្រប** : តើមធ្យោបាយនៃការដាក់កំហិតនេះវាសមស្រប( ប្រសិទ្ធិភាព) ឬទេ? និយាយម្យ៉ាងទៀត : តើមធ្យោបាយនៃការដាក់កំហិត ដែលអ្នកជ្រើសរើសវាស្របច្បាប់ទេ ហើយថាតើអ្នកអាចសម្រេចគោលដៅរបស់អ្នក ( ពោលគឺការការពារសិទ្ធិរបស់នរណាម្នាក់) ដោយប្រើមធ្យោបាយនេះទេ?

**ភាពចាំបាច់** : តើមធ្យោបាយនៃការដាក់កំហិតនោះវាចាំបាច់ឬទេ? និយាយម្យ៉ាងទៀត : តើមានមធ្យោបាយណាផ្សេងទៀតដែលមិនសូវខ្លាំងពេកទេ ? តើមានមធ្យោបាយណាដែលធូរស្រាលជាងនេះទេ?

<u>ឧទាហរណ៍:</u>

- ប៉ូលីសចង់ស៊ើបអង្កេតបទឧក្រិដ្ឋមួយ ។ គោលដៅរបស់គេគឺដើម្បីការពារជនរងគ្រោះ ។ ព្រោះហេតុដូច្នេះ ប៉ូលីសបានជ្រើសរើសការធ្វើទារុណកម្មជនសង្ស័យ ដើម្បីប្រមូលពត៌មាន ។

<u>សំណួរ: តើការធ្វើទារុណកម្មជនសង្ស័យ គឺជាមធ្យោបាយដែលសមាមាត្រក្នុងការដាក់កំហិតសិទ្ធិរបស់ជនសង្ស័យ ដើម្បីការពារជងរងគ្រោះឬទេ?</u>

<u>ចម្លើយ: អត់ទេ</u>។ វាមានប្រសិទ្ធិភាព ប៉ុន្តែវាមិនសមទេ ពីព្រោះមធ្យោបាយនៃការធ្វើទារុណកម្មវាមិនស្របច្បាប់ (សូមអានមាត្រា៣៨ CC: "ការបង្ខិតបង្ខំ , ការធ្វើបាបលើរាងកាយ ឬការធ្វើទុក្ខបុកម្នេញ ផ្សេងទៀតដែលបន្ថែមនូវទណ្ឌកម្មចំពោះជនជាប់ចោទ ឬអ្នកទោស ត្រូវបានហាមឃាត់ ") ។ ដូច្នេះ មធ្យោបាយនៃការធ្វើទារុណកម្ម វាមិនសមាមាត្រឡើយ ។

- រដ្ឋអំណាចចង់បញ្ឈប់បាតុករហិង្សា ដែលបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ។ រដ្ឋអំណាចនិយាយថាយើងមានជម្រើសតែពីរប៉ុណ្ណោះ។ យើងត្រូវបាញ់បាតុករ ឬក៏យើងត្រូវបណ្តោយឱ្យគេបន្តអំពើហិង្សាតទៅទៀត ។

<u>សំណួរ : តើការបាញ់បាតុករ គឺជាការដាក់កំហិតដែលសមាមាត្រ ដើម្បីការពារសិទ្ធិក្នុងការរក្សាទ្រព្យសម្បត្តិប្រជាពលរដ្ឋដែរឬទេ?</u>

ចម្លើយ : អត់ទេ វាមិនសមាមាត្រឡើយ ព្រោះវាមិនចាំបាច់ទេ ។ វាមានមធ្យោបាយនៃកាដាក់កំហិតដែលធូរស្រាលជាងនេះដែលគេត្រូវអនុវត្តមុនគេ។ ប្រសិនបើមធ្យោបាយទាំងនេះបញ្ជាក់ថាមិនសូវខ្លាំងទេ ជាជំហាន១ គេអាចប្រើប្រាស់មធ្យោបាយផ្សេងទៀត ។ គេអាចបាញ់បាតុករ ជាជម្រើសនៃមធ្យោបាយ ចុងក្រោយបំផុតតែប៉ុណ្ណោះ ក្នុងខណៈដែលបាតុករចាប់ផ្ដើមវាយប្រហារ និងសម្លាប់ប៉ូលីស ហើយប៉ូលីស ត្រូវតែធ្វើសកម្មភាពដើម្បីការពារខ្លួន។
ចម្លើយដែលសមាមាត្រ ដើម្បីដោះស្រាយទំនាស់រវាងសិទ្ធិរបស់បាតុករ និងសិទ្ធិក្នុងការរក្សាទ្រព្យសម្បត្តិមានចែងនៅក្នុងច្បាប់ស្ដីអំពីការធ្វើបាតុកម្ម (សូមអាន មាត្រា ៤, ៥ និង៦ នៃច្បាប់ស្ដីអំពីការធ្វើបាតុកម្ម) :

- ជាដំបូង ការធ្វើបាតុកម្មអាចត្រូវគេហាមឃាត់ ។
- បន្ទាប់មក ការហាមឃាត់នេះត្រូវប្រកាសចំនួនពីរលើកដល់បាតុករ ដើម្បីព្រមានពួកគេ ។
- ប្រសិនបើពួកគេនៅតែបន្ត ប៉ូលីសត្រូវគេអនុញ្ញាតឱ្យបំបែកហ្វូងបាតុករ ដោយមធ្យោបាយដែលមិនបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត។
- ប្រសិនបើបាតុករមានបំពាក់ដោយអាវុធ ប៉ូលីសត្រូវគេអនុញ្ញាតឱ្យចាប់ខ្លួនបាតុករបណ្ដោះអាសន្ន ហើយដកហូតយកអាវុធ ។ ក្រោយមកប៉ូលីសត្រូវដោះលែងគេ ហើយប្រគល់អាវុធអោយគេវិញ ប្រសិនបើអាវុធនោះមិនខុសច្បាប់ទេនោះ ។
- ប្រសិនបើបាតុករក្លាយទៅជាហិង្សា ប៉ូលីសអាចប្រើមធ្យោបាយ "សមាមាត្រ" ដើម្បីបញ្ឈប់ពួកគេ ។ មធ្យោបាយធូរស្រាលត្រូវប្រើមុនគេ (ព្រមាន , បាញ់ទៅលើ) ហើយការដាក់កំហិតខ្លាំងក្លាបំផុតត្រូវប្រើក្រោយគេ (បាញ់បាតុករដែលតដៃហើយមានកាន់អាវុធ)

**ទំនាក់ទំនងដែលពុំមានតុល្យភាពៈ**

សេរីភាពរបស់"ក" លើសលុបលើ សេរីភាពរបស់"ខ"




**ទំនាក់ទំនងដែលមានតុល្យភាពៈ** ច្បាប់បញ្ញត្តិអំពីការដាក់ព្រំដែនលើ"ក" ដើម្បីការពារ"ខ"



## ការដាក់ព្រំដែនតាមសមាមាត្រ




លំដាប់ថ្នាក់នេះ បង្ហាញពីការដាក់កំហិតខុសៗគ្នានៃការដាក់ព្រំដែនលើសេរីភាពរបស់បាតុករ( ឈ្មោះ"ក") ។ គោលការណ៍នៃភាពសមាមាត្រមានន័យថា មធ្យោបាយស្រាលៗនៃការដាក់កំរិតត្រូវបានយកមកប្រើមុនគេដែលមធ្យោបាយទាំងនោះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ "ក" (ដូចជា សិទ្ធិក្នុងការបញ្ចេញមតិរបស់គាត់ សិទ្ធិមានសុខភាពល្អ សិទ្ធិរស់រានមានជីវិត) តិចតួចបំផុត ។ ប៉ុន្តែបើមធ្យោបាយទាំងនោះប្រើទៅពុំមានប្រសិទ្ធិភាពទេ ជំហានបន្ទាប់មកទៀត គេត្រូវប្រើមធ្យោបាយខ្លាំងជាងមុន ។